# សេចក្តីជូនដំណឹង

## ការធ្វើបច្ចុប្បន្នភាពសុវត្ថិភាពរបស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស (E-Filing)

## TWO-FACTOR AUTHENTICATION

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ........✓.............ន. គ. ស .......

ថ្ងៃអង្គារ ២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពីការបន្ថែមមុខងារផ្ទៀងផ្ទាត់ (2FA) ដើម្បីពង្រឹងសុវត្ថិភាពគណនីអ្នកប្រើប្រាស់ ក្នុងប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស (E-Filing)

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ សហគ្រាសទាំងអស់ឲ្យបានជ្រាបថា៖ កន្លងមក **ន.គ.ស.** បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស (E-Filing) អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ដើម្បីបង្កើនសុវត្ថិភាពប្រព័ន្ធ ការការពារទិន្នន័យរបស់អ្នកប្រើប្រាស់ និងភាពត្រឹមត្រូវក្នុងការចូលប្រើប្រាស់ប្រព័ន្ធ E-Filing **ន.គ.ស.** បានបន្ថែមមុខងារសុវត្ថិភាពការផ្ទៀងផ្ទាត់អត្តសញ្ញាណពីរជាន់ 2FA (Two-Factor Authentication) ត្រូវបានបើកសម្រាប់គណនីទាំងអស់ ដែលតម្រូវឲ្យអ្នកប្រើប្រាស់ត្រូវបញ្ចូលពាក្យសម្ងាត់ជាមួយ និងលេខកូដផ្ទៀងផ្ទាត់ (OTP) តាមអ៊ីម៉ែលដែលបានចុះឈ្មោះ នៅពេលចូលប្រើប្រាស់ប្រព័ន្ធ។ ***ក្នុងករណីដែលសហគ្រាសណាមួយមិនអាចចូលប្រើប្រាស់អ៊ីម៉ែលដែលបានចុះឈ្មោះក្នុងប្រព័ន្ធ E-Filing បាន ដូចនេះសហគ្រាសត្រូវធ្វើបច្ចុប្បន្នភាព ឬផ្លាស់ប្តូរអ៊ីម៉ែលថ្មីដែលអាចចូលប្រើប្រាស់បានឲ្យបានឆាប់រហ័ស*** ដើម្បីជៀសវាងការរាំងស្ទះក្នុងការចូលប្រើប្រាស់ប្រព័ន្ធដែលអាចនាំឱ្យមានផលប៉ះពាល់ ឬយឺតយ៉ាវដល់ការបំពេញកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុស្របតាមពេលកំណត់ និងបទប្បញ្ញត្តិជាធរមាន។

**ន.គ.ស.** សង្ឃឹមយ៉ាងមុតមាំថា សហគ្រាសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយម៉ឺងម៉ាត់ និងទាន់ពេលវេលា។

**និយ័តករគណនេយ្យនិងសវនកម្ម**


ទំនាក់ទំនង៖

លោក ហាក់ សីហា ០៩៦ ៩១៩ ៩៩៩៨

លោក យន់ ស៊ីវត្ថា ០១៥ ២៨៦ ១២០